ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :..០៧៣.សព្រក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ផលប៉ះពាល់តំបន់ និងជនស៊ីវិលកម្ពុជា ដោយអំពើឈ្លានពានរបស់ភាគីថៃ លើដែនអធិបតេយ្យកម្ពុជា ពីម៉ោង១រសៀល ដល់ម៉ោង៦ល្ងាច ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង១រសៀល រហូតដល់ម៉ោង៦ល្ងាច ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥នេះ អំពើឈ្លានពានរបស់រដ្ឋាភិបាល និងយោធាថៃ ជាពិសេសការផ្លោង និងទម្លាក់គ្រាប់គ្រប់ប្រភេទ គ្រប់ទម្រង់ ចូលតំបន់ស៊ីវិល បានបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួសថ្មី៖** មានពលរដ្ឋរបួស១នាក់ នៅខេត្តបន្ទាយមានជ័យ។ គិតសរុបពីថ្ងៃទី៧ ខែធ្នូ មកដល់ពេលនេះ មានពលរដ្ឋស្លាប់ចំនួន៣០នាក់ (បូកបន្ថែមពលរដ្ឋភៀសសឹកដែលបានស្លាប់សរុបចំនួន៩នាក់ជាបន្តបន្ទាប់នៅជំរំភៀសសឹកខេត្តសៀមរាប) និងរបួសចំនួន៨៧នាក់។

**២-ករណីពលរដ្ឋនៅជំរំភៀសសឹក៖** គិតសរុបពីថ្ងៃទី៧ ខែធ្នូមក មានជនភៀសសឹកសរុប **៦៣៦.៥៣៦នាក់** ក្នុងនោះស្ត្រី ៣៣១.៧០៧នាក់ និងកុមារ២០២.៤៥៥នាក់។ តួលេខនេះ អាចមានការប្រែប្រួលជាបន្តបន្ទាប់ទៀត។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិលថ្មី៖ ខូចខាតផ្ទះ២ខ្នង** នៅខេត្តបាត់ដំបង។ គិតសរុបពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** រួមមាន ផ្ទះពលរដ្ឋ១២៥ខ្នង អគារឯកជន៦ទីតាំង អគារស្នាក់នៅ/សណ្ឋាគារ៥ទីតាំង ស្ថានីយ៍ប្រេង១ទីតាំង រថយន្ត២៧គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១កន្លែង អគារឃ្លាំងទំនិញ១កន្លែង បង្គោលអង់តែនទូរសព្ទ២កន្លែង។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** រួមមាន សាលារៀន៦កន្លែង មណ្ឌលសុខភាព២កន្លែង អគារ១២កន្លែង វត្ត៥កន្លែង សាលាឆទាន១កន្លែង រថយន្ត១គ្រឿង ប្រាសាទបុរាណមួយចំនួន ស្ពាន៥កន្លែង ផ្សារ១កន្លែង និងផ្លូវ២កន្លែង។ មកដល់ពេលនេះ មានប្រជាជនកម្ពុជាជាងកន្លះលាននាក់ រួមមានស្ត្រីជាង៥០% និងកុមារជាង៣០% កំពុងរងទុក្ខ បន្ទាប់ពីបង្ខំចិត្តភៀសសឹក គេចពីគ្រាប់កាំភ្លើង គ្រាប់ផ្លោងតូចធំ និងការទម្លាក់គ្រាប់ពីយន្តហោះ ដែលបំផ្លាញផ្ទះសំបែង សាលារៀន និងភូមិករពួកគាត់ជាបន្តបន្ទាប់រួចទៅហើយ។ ជាក់ស្តែងនៅស្រុកបាណន់ ខេត្តបាត់ដំបង ថ្ងៃនេះ កុមារតូចៗ និងសិស្សជាច្រើនរយនាក់ បានសម្រុករត់ចេញពីសាលារៀន ខ្លះវង្វេងឪពុកម្តាយ ព្រោះតែភិតភ័យដោយសារយន្តហោះថៃទម្លាក់គ្រាប់។

ព្រោះហេតុដូច្នេះ យើងនៅតែអំពាវនាវមិត្តបរទេស ជាពិសេសអាមេរិក ចិន ម៉ាឡេស៊ី និងមិត្តអាស៊ានបន្តសកម្មភាព ជ្រោមជ្រែងពន្លត់ភ្លើងសង្គ្រាមជាស្ថាពរ នាំមកនូវសន្តិភាពជាអចិន្ត្រៃយ៍ ដែលជាបំណងប្រាថ្នាតាំងពីដើមរបស់កម្ពុជា។ ដូចជំហរកម្ពុជាក្នុងកិច្ចប្រជុំពិសេសរដ្ឋមន្ត្រីការបរទេសអាស៊ានបញ្ជាក់ថា **កម្ពុជាចង់ដោះស្រាយជម្លោះ ការកំណត់ខ័ណ្ឌសីមាព្រំដែន តាមរយៈមធ្យោបាយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ សន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ព្រមទាំងសន្ធិសញ្ញា និងយន្តការដែលមានស្រាប់។**

ក្រសួងមហាផ្ទៃ នៅតែបន្តកត់ត្រាទុក ដោយក្តីមោទនយ៉ាងក្រៃលែងបំផុត ដែលកូនខ្មែរគ្រប់រូប បានកំពុងបន្តវេញស្មារតីប្រកៀកស្មា គាំទ្រយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត**។ មហាកម្លាំងសាមគ្គីនេះ បានផ្តល់ថាមពលដ៏មហិមាជូនវីរយុទ្ធជនជួរមុខមាន កងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែន ដែលកំពុងប្រយុទ្ធការពារបូរណភាពទឹកដីយ៉ាងអង់អាចជាញជ័យ។ សូមជនរួមជាតិបន្តពង្រឹងស្មារតីព្រលឹងខ្មែរតែមួយនេះឱ្យបានឋិតនៅជានិរន្តរ៍...។

ថ្ងៃពុធ ៥កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥